# ក្រមសីលធម៌

# ការរាយការណ៍លើករណីហិង្សារបស់បុរសទៅលើស្ត្រី

*មុនពេលសម្ភាសជនរងគ្រោះពីការប្រើប្រាស់ហិង្សារបស់បុរសទៅលើស្ត្រី សូមធ្វើឱ្យប្រាកដថា អ្នកបានធ្វើតាមសំណួរនីមួយៗខាងក្រោម និងធ្វើតាម "បញ្ជីត្រួតពិនិត្យពីការរាយការណ៍លើការបញ្ឈប់អំពើហិង្សាលើស្ត្រី" ឱ្យបានជិតដល់។*

**1. តើរឿងនេះបានគិតគូរថា សុវត្ថិភាព សេចក្ដីថ្លៃថ្នូរ និងប្រយោជន៍ខ្លាំងបំផុតរបស់ជនគ្រោះមានសារសំខាន់ជាងឬទេ?**

---

**សុវត្ថិភាព ភាពថ្លៃថ្នូរ និង ប្រយោជន៍ខ្លាំងបំផុតរបស់ជនរងគ្រោះត្រូវតែនៅអាទិភាពលេខមួយជានិច្ច។** ជនរងគ្រោះស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ហើយការការពាររបស់ពួកគេគឺចាំបាច់បំផុត។ ការធ្វើសម្រាប់ផលប្រយោជន៍ខ្លាំងបំផុតរបស់ជនរងគ្រោះគឺមានន័យថាការដាក់បញ្ចូលតម្រូវការរបស់ពួកគេជាមុន និងការគោរពឯកជនភាពរួមទាំងអារម្មណ៍របស់ជនរងគ្រោះ បើទោះបីជាមានន័យថាកិច្ចសម្ភាសឬរឿងរ៉ាវត្រូវកែប្រែខុសពីអ្វីដែលអ្នកផលិតកម្មវិធី បានរំពឹងនិងគ្រោងទុកជាមុនរួចហើយក្ដី។ ជនរងគ្រោះមិនគួរត្រូវបានដាក់សម្ពាធឱ្យលាតត្រដាងព័ត៌មានច្រើនជាងអ្វីដែលពួកគេមានអារម្មណ៍កក់ក្ដៅក្នុងការនិយាយនោះទេ។

អ្នកផលិតកម្មវិធី គួរតែគិតគូរជានិច្ចថា គ្រែងលោនិងរបៀបដែលរឿងមួយអាចមានលទ្ធភាពរំលោភបំពានទៅលើសិទ្ធិសំខាន់ៗរបស់ជនរងគ្រោះ។ នេះរួមមានការពិចារណាពីសិទ្ធិរបស់ជនរងគ្រោះលើភាពថ្លៃថ្នូរ សិទ្ធិទទួលបានឯកជនភាព សិទ្ធិទទួលបានការរក្សាការសម្ងាត់ សិទ្ធិទទួលបានសុវត្ថិភាព សិទ្ធិទទួលបានសន្តិសុខ និងសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់ឬទណ្ឌកម្ម។ ប្រសិនបើជនរងគ្រោះមិនចង់ឲ្យអ្នកផលិតកម្មវិធីរាយការណ៍ពីរឿងរបស់គាត់ អ្នកផលិតកម្មវិធីគួរតែគោរពតាមបំណងរបស់ជនរងគ្រោះនិងបញ្ចប់ការរាយការណ៍។

ចូរពិចារណាចំណុចខាងក្រោមប្រសិនបើសម្ភាសជនរងគ្រោះណាមួយសម្រាប់ដាក់ក្នុងរឿង៖

- កុំបង្ហាញឈ្មោះរបស់ជនរងគ្រោះ។
- កុំបង្ហាញទីកន្លែងរបស់ជនរងគ្រោះក្នុងព័ត៌មានលម្អិតជាងឃុំ ឬស្រុក ឬ ខេត្តរបស់ពួកគេ។
- កុំបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់សមាជិកគ្រួសារជនរងគ្រោះ (រួមទាំងឈ្មោះ)។
- កុំបង្ហាញឈ្មោះឬមុខរបស់ក្មេងដែលជាប់ពាក់ព័ន្ធជាមួយជនរងគ្រោះ ឬជនល្មើស។
- កុំបង្ហាញឈ្មោះជនល្មើសដោយសារវាអាចនាំឱ្យស្គាល់អត្តសញ្ញាណជនរងគ្រោះ។
- កុំបង្ហាញទីកន្លែងរបស់ជនល្មើសនៅក្នុងព័ត៌មានលម្អិតជាងឃុំរបស់ពួកគេ។
- ប្រើប្រាស់រូបថតរបស់ជនរងគ្រោះបានលុះត្រាតែចាំបាច់បំផុត។ ប្រសិនបើវាចាំបាច់ត្រូវប្រើរូបថតជនរងគ្រោះ ត្រូវធានាថាមិនអាចរកដឹងអត្តសញ្ញាណរបស់ជនរងគ្រោះ និងបង្ហាញរូបដោយរក្សាសេចក្ដីថ្លៃថ្នូររបស់គាត់។ ការធានានេះមានរួមទាំងការលាក់មុខនិងទម្រង់អ្វីៗផ្សេងទៀតដែលអាចបញ្ជាក់ពីអត្តសញ្ញាណបាន រួមបញ្ចូលទាំងផ្ទាំងខាងក្រោយនៃរូបថត។ បើសិនរូបភាពត្រូវបានបង្ហោះតាមបណ្ដាញអនឡាញឌីជីថល ត្រូវធានាថាឬសគល់ព័ត៌មាន (meta) ឬទិន្នន័យ

មិនអនុញ្ញាតឱ្យកំណត់រកមើលដឹងអត្តសញ្ញាណរបស់បុគ្គលនោះ ដោយមានរួមទាំងទីកន្លែងរបស់ពួកគេ។

- តែងតែស្នើផ្តល់ការផ្សាភ្ជាប់ជនរងគ្រោះទៅនឹងសេវាជំនួយដែលមាន ហើយពាក់ព័ន្ធនឹងបញ្ហារបស់ជនរងគ្រោះ។

## 2. តើមុំនៃរឿងនេះមានសារច្បាស់លាស់ដែលត្រូវជាមួយគោលដៅនិងវត្ថុបំណងរបស់វគ្គវិទ្យុដែរឬទេ?

គ្រប់ករណីហិង្សាត្រូវតែជាប់ពាក់ព័ន្ធទៅនឹងគោលដៅនិងវត្ថុបំណងរបស់វគ្គនៃកម្មវិធី"យើងធ្វើបាន" ដើម្បីប្រាកដថា វាត្រូវបានគាំទ្រដោយវគ្គដទៃផ្សេងទៀតរបស់កម្មវិធី និងត្រូវបង្ហាញក្នុងបរិបទទូលំទូលាយ។ ករណីហិង្សាមិនគួរត្រូវបានប្រើប្រាស់ក្នុងគោលបំណងនៃកម្មវិធីកំសាន្តនោះទេ។

គួរចងចាំថាកម្មវិធី"យើងធ្វើបាន" គឺជាផ្នែកនៃអភិបាលកិច្ចនិងការទទួលខុសត្រូវរបស់អាជ្ញាធរ។ ដូច្នេះ ករណីរឿងបុគ្គលទាំងឡាយគួរតែផ្តោតលើសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន មិនមែនជាបទពិសោធន៍នៃអំពើហិង្សារបស់បុគ្គលណាម្នាក់។

## 3. តើអ្នកផលិតកម្មវិធីបានដឹងពីការផ្លាស់ប្តូរជាហូរហែរនូវស្ថានភាព របស់ជនរងគ្រោះដែរឬទេ?

អ្នកផលិតកម្មវិធីត្រូវតែដឹងថា បើទោះបីជាស្ថានភាពហិង្សាទំនងជាស្ងប់ស្ងាត់ហើយក្តី ក៏វាប្រហែលជាមិនត្រូវការអ្វីច្រើនដើម្បីឱ្យ បញ្ហានេះផ្ទុះឡើងជាថ្មីម្តងទៀតនោះទេ។ អ្នកផលិតកម្មវិធីត្រូវដឹងពីស្ថានភាពបុគ្គលនីមួយៗមុនពួកគេធ្វើការសម្ភាសណាមួយ ហើយវាយតម្លៃថាតើការជ្រៀតជ្រែកតាមរយៈការធ្វើរឿងសម្រាប់កម្មវិធីរបស់ខ្លួន ទំនងនឹងធ្វើឱ្យស្ថានភាពកាន់តែដុនដាបដែរឬទេ។ ប្រសិនបើជនរងគ្រោះនៅតែស្ថិតក្នុងជំហរមានគ្រោះថ្នាក់ ឬមិនអាចទទួលសេវាគាំទ្របាន អ្នកផលិតកម្មវិធី ទំនងមិនអាចមើលឃើញបញ្ហាទាំងមូល ហើយគួរតែពិចារណាឡើងវិញ នូវការធ្វើសម្ភាសឬការផ្សាយព័ត៌មាននៅដំណាក់កាលនេះ។

ប្រសិនបើបទសម្ភាសជាមួយជនរងគ្រោះដោយការរំលោភបំពានត្រូវបានធ្វើឡើងជាច្រើនសប្តាហ៍ឬជាច្រើនខែមុននឹងផ្សាយលើរលកធាតុអាកាស អ្នកផលិតកម្មវិធីគួរតែព្យាយាមទាក់ទងជនរងគ្រោះជាថ្មីមុននឹងផ្សាយរឿងចេញ ដើម្បីធ្វើឱ្យប្រាកដថា ស្ថានភាពរបស់គាត់មិនបានផ្លាស់ប្តូរចាប់តាំងពីផ្តល់បទសម្ភាសមក និងធានាថារឿងដែលត្រៀមចេញផ្សាយនឹងមិនបង្កឱ្យមានការប៉ះទង្គិចអារម្មណ៍ជាថ្មី ឬដាក់ជនរងគ្រោះក្នុងស្ថានភាពគ្រោះថ្នាក់ឡើយ។

ការសងសឹកដាក់ទណ្ឌកម្មពីជនបង្កហិង្សា គ្រួសារ ឬសហគមន៍ ដោយសារលទ្ធផលនៃការផ្តល់បទសម្ភាសឬសាច់រឿង គួរតែត្រូវបានពិចារណាឱ្យបានខ្លាំង ដោយសារអ្នកផលិតកម្មវិធី អាចធ្វើឱ្យជនរងគ្រោះកាន់តែមានគ្រោះថ្នាក់ខ្លាំងឡើង។

ប្រសិនបើជនរងគ្រោះមិនចង់និយាយជាមួយអ្នកផលិតកម្មវិធីពីបទពិសោធន៍របស់គាត់ អ្នកផលិតកម្មវិធីមិនគួរស្វែងរកព័ត៌មានបន្ថែមលើករណីហិង្សានេះពីអ្នកជិតខាង ឬសមាជិកគ្រួសារនោះទេ។ នេះអាចជាការទទួលបាន

ព័ត៌មានលម្អិតដោយគ្មានការអនុញ្ញាតពីជនរងគ្រោះ ហើយព័ត៌មានផ្តល់ដោយអ្នកក្រៅ ទំនងជាមិនត្រឹមត្រូវ (បើទោះបីជាអ្នកក្រៅទាំងនោះស្គាល់ជនរងគ្រោះច្បាស់ក៏ដោយ)។

អ្នកផលិតកម្មវិធីគួរដឹងនិងទាក់ទងជាមួយអ្នកជំនាញខាងបញ្ឈប់អំពើហិង្សាលើស្ត្រី (មានដូចជាអង្គការពាក់ព័ន្ធ មន្ទីរកិច្ចការនារីខេត្ត ។ល។) ដើម្បីបញ្ជូនករណីជាក់ស្តែងនៃអំពើហិង្សាលើស្ត្រី និងសុំប្រឹក្សាយោបល់ព្រមទាំងការចូលរួមនៅពេលចាំបាច់។

## 4. តើរឿង "បញ្ឈប់អំពើហិង្សាលើស្ត្រី" នេះអាចផ្តល់នូវបរិបទសង្គមមួយសម្រាប់ហិង្សាលើស្ត្រីដែរឬទេ?

**ហិង្សាក្នុងគ្រួសារគឺជាបញ្ហាសង្គមមួយដែលកើតចេញពីការរើសអើងយេនឌ័រ។** អ្នកផលិតកម្មវិធីគួរដឹងថា នៅពេលហិង្សាទំនងមើលទៅដូចជាបញ្ហាពិសេសតែមួយ ឬ កើតឡើងតែម្តងក្តី ក៏វាគឺជាផ្នែកនៃលំនាំមួយដែលរឹតតែទូលំទូលាយជាងនេះទៅទៀត។

វាមានសារសំខាន់ចំពោះការរាយការណ៍ពីការបញ្ឈប់អំពើហិង្សាលើស្ត្រីនិងការតស៊ូមតិដើម្បីទទួលស្គាល់ថា អំពើហិង្សាលើស្ត្រីកើតឡើងដោយសារតែការកើតមាននៃវិសមភាពយេនឌ័រ។ នៅពេលពិចារណាពីហិង្សាលើស្ត្រី យើងត្រូវតែគិតគូរពីសមភាពយេនឌ័រ "ដោយសារហិង្សាលើស្ត្រីត្រូវបានបង្កឡើងដោយសារអតុល្យភាពនៃអំណាចរវាងស្ត្រីនិងបុរស និងឱ្យជំនឿនិងការរំពឹងទុកដ៏ចង្អៀតចង្អល់អំពីរបៀបដែលស្ត្រីនិងបុរសគួរប្រព្រឹត្ត"[1]។ វិសមភាព និងការរើសអើងយេនឌ័រធ្វើឱ្យកាន់តែងាយសម្រាប់ចាត់ទុកអំពើហិង្សា លើស្ត្រីថាជារឿងទូទៅ ទទួលយកបាន និងធម្មតា។

គួរកត់សម្គាល់ពីកត្តាហានិភ័យផងដែរ ដូចជាការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬភាពក្រីក្រ មិនមែនជាឫសគល់នៃអំពើហិង្សាលើស្ត្រីនោះទេ ប៉ុន្តែវាអាចរួមចំណែកធ្វើឱ្យស្ថានភាពនេះកាន់តែអាក្រក់។

ដូច្នេះ ការរាយការណ៍ពីការបញ្ឈប់អំពើហិង្សាលើស្ត្រីគួរពិនិត្យលើបទដ្ឋានសង្គមនិងវប្បធម៌។ រឿងដោយឡែកទាំងឡាយនៃអំពើហិង្សាលើស្ត្រី គឺគ្រាន់តែជាចំណែកតូចមួយនៃបញ្ហា។

យ៉ាងតិចបំផុត អ្នកផលិតកម្មវិធីគួរតែផ្តល់ដល់អ្នកស្តាប់នូវស្ថិតិអំពីភាពទូទៅនៃអំពើហិង្សាលើស្ត្រី ដើម្បីជួយបង្ហាញពីលំនាំទាំងនេះនៅក្នុងសង្គម។ ស្ថិតិទាំងនេះអាចបានមកពីប្រភពថ្នាក់មូលដ្ឋាន ជាតិ ឬអន្តរជាតិ។

## 5. តើរឿងរ៉ាវហិង្សារបស់ជនរងគ្រោះម្នាក់ គឺជាវិធីល្អបំផុតក្នុងការផ្តល់សារដែលយើងមានចេតនាឬទេ?

អ្នកផលិតកម្មវិធីនិងប្រព័ន្ធផ្សព្វផ្សាយដែលមានជំនាញវិជ្ជាជីវៈ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការបញ្ឈប់អំពើហិង្សាលើស្ត្រី ប៉ុន្តែក៏ត្រូវប្រឆាំងនឹងជំនឿនិងឥរិយាបថហួសសម័យដែលទំនងបន្តកើតមានលើបញ្ហានេះផងដែរ។ ដើម្បីជៀសវាងការធ្វើឱ្យជនរងគ្រោះនៃអំពើហិង្សាយេនឌ័ររឹតតែរងគ្រោះបន្ថែមទៀត អ្នកផលិតកម្មវិធីគួរតែផ្តោតមុំរឿងរបស់ពួកគេ ដោយពិនិត្យលើការទទួលខុសត្រូវ

[1] "How to design projects to end violence against women and girls", UN Women, 2015

និងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីចាត់វិធានការលើសកម្មភាពអំពើហិង្សាលើស្ត្រីនិងកុមារី ហើយផ្តល់ព័ត៌មានសំខាន់ដល់អ្នកស្តាប់ពីទីកន្លែងដែលអាចស្វែងរកសេវាជំនួយជួយជនរងគ្រោះ ដែលធ្វើការលើការបញ្ឈប់អំពើហិង្សាលើស្ត្រីនិងកុមារី។

ជាជាងការផ្តោតលើសាច់រឿងរបស់ជនរងគ្រោះ ជនល្មើសនិងសកម្មភាពជាក់ស្តែងនៃអំពើហិង្សា ការយកចិត្តទុកដាក់លើរឿងរ៉ាវវិជ្ជមាននៃការផ្តល់អំណាចនិងភាពរឹងមាំឡើងវិញរបស់ស្ត្រី អាចជួយក្នុងការបង្ហាញពីវិធីដែលជនរងគ្រោះជាញឹកញាប់ដើរតួនាទីជាអ្នកតស៊ូមតិនិងភ្នាក់ងារនៃការផ្លាស់ប្តូរ។ អ្នកផលិតកម្មវិធីអាចលើកឡើងនូវការផ្សាភ្ជាប់រវាងផ្នែកខ្លឹមសារផ្សេងៗគ្នា ដូចជា៖

- ការផ្តល់អំណាចសេដ្ឋកិច្ចនិងឱកាសល្អ៖
  - ស្ត្រីដែលជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារគឺច្រើនពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើស្វាមីរបស់គាត់។ រឿងរ៉ាវទាក់ទងមួយអាចអំពីស្ត្រីដែលទទួលបានចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងមានឱកាសផ្នែកសេដ្ឋកិច្ចដែលបានធ្វើឱ្យគាត់គេចចេញឬប្រាប់ពីស្ថានភាពអំពើហិង្សា។
- សំឡេងប្រជាធិបតេយ្យនិងការសម្រេចចិត្តរបស់ស្ត្រី
  - ស្ត្រីមានសិទ្ធិស្មើនឹងបុរសដើម្បីក្លាយជាអ្នកសម្រេចចិត្តនិងអ្នកដឹកនាំ ទាំងក្នុងវិស័យឯកជននិងសាធារណៈ។ រឿងរ៉ាវមួយអាចរៀបរាប់ពីអ្នកនយោបាយស្ត្រីម្នាក់ដែលកំពុងលើកកម្ពស់ការយល់ដឹងពីការបញ្ឈប់អំពើហិង្សាលើស្ត្រី និងអប់រំស្ត្រីមូលដ្ឋានពីសិទ្ធិរបស់ពួកគេចំពោះជីវិតមួយដែលគ្មានហិង្សា។
- ការជំទាស់ផ្ទត់គំនិតយេនឌ័រ៖
  - ដោយការផ្លាស់ប្តូរឥរិយាបទជុំវិញតួនាទីយេនឌ័រជាប្រពៃណី យើងក៏ផ្លាស់ប្តូរភាពមិនស្មើគ្នានៃអំណាចរវាងបុរសនិងស្ត្រីផងដែរ។ រឿងរ៉ាវមួយអំពីបុរសម្នាក់ដែលស្តាប់កម្មវិធី"យើងធ្វើបាន" ញឹកញាប់ និងដឹងថាការវាយធ្វើបាបប្រពន្ធរបស់គាត់គឺជាអាកប្បកិរិយាមិនអាចទទួលយកបាន ដូច្នេះគាត់ផ្លាស់ប្តូរអាកប្បកិរិយារបស់គាត់។

អ្នកផលិតកម្មវិធីត្រូវតែដឹងថា សេចក្តីលម្អិតពិស្តារពីការរំលោភបំពានផ្លូវភេទនិងហិង្សា អាចបង្កឱ្យមានផលប៉ះពាល់ផ្លូវអារម្មណ៍ខ្លាំងចំពោះអ្នកស្តាប់ដែលមានបទពិសោធន៍ផ្ទាល់ឬស្គាល់នរណាម្នាក់ដែលធ្លាប់ប្រទះបញ្ហាទាំងនេះ ដូចជាឪពុកដែលមានកូនស្រីត្រូវបានចាប់រំលោភសេពសន្ថវៈឬសម្លាប់។ អ្នកផលិតកម្មវិធីគួរតែពិចារណាពីផលប៉ះពាល់ដែលរឿងរបស់ពួកគេនឹងមានលើបុគ្គលអ្នកស្តាប់ដទៃទៀត។ ការផ្សាភ្ជាប់រឿងទៅនឹងសេវាជំនួយផ្សេងៗគឺសំខាន់សម្រាប់ជនរងគ្រោះដោយការរំលោភបំពានដែលជាអ្នកស្តាប់។

## 6. តើរឿងនេះជៀសផុតពីការស្តីបន្ទោសជនរងគ្រោះដែរឬទេ?

អ្នកផលិតកម្មវិធីគួរតែប្រុងប្រយ័ត្នក្នុងការដាក់បញ្ចូលតែព័ត៌មានពាក់ព័ន្ធពីជនរងគ្រោះនៅក្នុងរឿងប៉ុណ្ណោះ។ ឧទាហរណ៍៖ ការផ្តល់មតិយោបល់ពីរបៀបជនរងរគ្រោះស្លៀកពាក់ (ឧ៖ ស្លៀកពាក់ស៊ិចស៊ី ឬ ស្លៀកសំពត់ខ្លី) ស្ត្រីបានឬមិនបានទទួលទានគ្រឿងស្រវឹង ឬថាតើស្ត្រីនោះដើរទៅផ្ទះតែម្នាក់ឯងពេលយប់ដែរឬទេ អាចនាំឱ្យមានការស្តីបន្ទោសលើជនរងគ្រោះ។ ការរាយការណ៍ព័ត៌មានទាំងនេះបង្កប់ន័យស្តីបន្ទោសលើជនរងគ្រោះ

ដែលអាចនឹងបំផ្លាញស្រ្តី និងជារឿងមិនពិតផងដែរ។ ការបំពានលើស្រ្តីបានកើតឡើងដោយសារជនល្មើសបានសម្រេចចិត្តបំពានលើជនរងគ្រោះ។

បើមិនពាក់ព័ន្ធដោយសមហេតុផលទៅនឹងសាច់រឿងទេនោះអ្នកផលិតកម្មវិធីមិនគួររាយការណ៍អំពីជាតិសាសន៍របស់ជនរងគ្រោះនិងជនល្មើសឡើយ។ ក្នុងនោះផងដែរ ការប្រើប្រាស់ភាសារក៏មានសារសំខាន់ ដោយសារវាអាចបង្កប់ជំនឿនិងការមិនជឿចំពោះការកើតឡើងនៃបទឧក្រិដ្ឋ។ ត្រូវហៅស្រ្តីដែលបានជួបប្រទះនឹងអំពើហិង្សាថាជា "ជនរងគ្រោះ" មិនមែនជា "ដើមចោទ"ឡើយ។

បន្ថែមពីនេះ សកម្មភាពរបស់ជនល្មើសគួរតែមិនទទួលបាននូវលេស ឬទទួលបានអារម្មណ៍អាណិតអាសូរនោះទេ។ ឧទាហរណ៍៖ ការយោងអំពីលក្ខណៈសម្បត្តិពីសមាជិកគ្រួសារដែលនិយាយថា "មនុស្សរាល់គ្នាអាចធ្វើខុស" ឬពណ៌នាអំពីជនល្មើសថាជា "បុរសល្អដែលជាធម្មតាមិនបង្កបញ្ហាចំពោះនរណាឡើយ" ពង្រឹងបន្ថែមនូវការស្តីបន្ទោសលើជនរងគ្រោះ។

អំពើហិង្សាលើស្រ្តីកើតឡើងដោយសារនរណាម្នាក់ (ធម្មតាជាបុរស) ប្រព្រឹត្តហិង្សានេះ។ វាមិនដែលជាកំហុសរបស់ជនរងគ្រោះនោះទេ។

## 7. តើរឿងនេះផ្តល់ព័ត៌មានដល់អ្នកស្តាប់ពីទីកន្លែងដែលពួកគេអាចទទួលជំនួយដែរឬទេ?

នៅចុងវគ្គនីមួយៗនៃកម្មវិធីបញ្ឈប់អំពើហិង្សាលើស្រ្តី អ្នកផលិតកម្មវិធីគួរតែផ្តល់ព័ត៌មានដល់អ្នកស្តាប់ពីសេវាជំនួយដែលមាននៅថ្នាក់មូលដ្ឋាន រួមបញ្ចូលទាំងលេខទូរសព្ទទំនាក់ទំនងនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិដែលពួកគេអាចទាក់ទងទៅបានបើចាំបាច់។ អ្នកផលិតកម្មវិធីគួរតែមានការអនុញ្ញាតពីកន្លែងផ្តល់សេវាជំនួយមុននឹងផ្សព្វផ្សាយលេខទំនាក់ទំនងតាមវិទ្យុ។